# ដំណើរការ SEPA

# ពន្ធនាគារក្រុង Seattle

### *តើ SEPA ជាអ្វី ?*

- SEPA គឺជា State Environmental Policy Act (ច្បាប់គោលនយោបាយបរិស្ថានរបស់រដ្ឋ) ដែលជាច្បាប់រដ្ឋមួយ តម្រង់ទិសដល់ភ្នាក់ងារទាំងអស់ ឱ្យពិចារណាពីព័ត៌មានស្តីពីបរិស្ថាន មុនពេលអនុវត្តគម្រោងជាក់លាក់ណាមួយ ព្រមទាំងត្រូវលើកទឹកចិត្តឱ្យមានការចូលរួមពីសាធារណៈជនក្នុងការសំរេចចិត្តរបស់ខ្លួន ។
- ចំពោះគម្រោងណាដែលស្ថិតនៅទីក្រុង Seattle ក្រុង ជាធម្មតាត្រូវអនុវត្តដំណើរការ SEPA នេះ ។ ក្រុងមានសិទ្ធិសំរេច ថាតើ Environmental Impact Statement (EIS) [របាយការណ៍ផលប៉ះពាល់បរិស្ថាន] តម្រូវឱ្យមានឬទេ ចំពោះគំរោងដែលបានផ្តល់ឱ្យនៅក្នុងកម្រិតកំណត់របស់ទីក្រុងខ្លួន ។

### *តើ EIS ជាអ្វី ?*

- Environmental Impact Statement (EIS) [របាយការណ៍ផលប៉ះពាល់បរិស្ថាន] គឺជាគោលដៅ ការវាយតម្លៃដោយមិនលំអៀងពីផលប៉ះពាល់បរិស្ថាន នៃគម្រោងដែលបានស្នើឡើង ។
    - o EIS គឺជាឧបករណ៍មួយប្រើប្រាស់ដោយទីក្រុង ភ្នាក់ងារផ្សេងៗទៀត និងសាធារណៈជន ក្នុងដំណើរការធ្វើការសំរេចចិត្ត ។
    - o EIS មិនផ្តល់យោបល់ឱ្យ ឬប្រឆាំងទៅនឹងវិធានការណ៍ណាមួយឡើយ ។

### *តើជំហានធំៗនៃដំណើរការ EIS មានអ្វីខ្លះ ?*

- 1) ការសិក្សាត្រួតពិនិត្យ – ទាមទារឱ្យមានរយៈពេលប្រមូលមតិយោបល់សាធារណៈជនអប្បបរមា 21 ថ្ងៃ ។
- 2) ពង្រៀង EIS – រួមទាំងទាមទាររយៈពេលប្រមូលមតិយោបល់សាធារណៈជនលើកទី 2 (30 ទៅ 45 ថ្ងៃ) ។
- 3) EIS ចុងក្រោយ

### *តើគោលបំណងនៃការសិក្សាត្រួតពិនិត្យ EIS មានអ្វីខ្លះ?*

- ការសិក្សាត្រួតពិនិត្យផ្តល់នូវសេចក្តីជូនដំណឹងទៅឱ្យភ្នាក់ងារ អង្គការផ្សេងៗ និងសាធារណៈជនថា EIS នឹងត្រូវរៀបចំឡើងសំរាប់គម្រោងដែលបានស្នើឡើង ។
- គោលបំណងនៃការសិក្សាត្រួតពិនិត្យ គឺដើម្បីប្រមូលមតិយោបល់សាធារណៈ និងភ្នាក់ងារផ្សេងៗស្តីពីបញ្ហាបរិស្ថាន ព្រមទាំងជំរើសនានាដើម្បីដោះស្រាយនៅក្នុង EIS ។

### *តើសាធារណៈជនអាចផ្តល់ព័ត៌មានដោយរបៀបណា ក្នុងអំឡុងពេលសិក្សាត្រួតពិនិត្យ ?*

- ក្រុងនឹងកំណត់រយៈពេលផ្តល់យោបល់លើដែនកំណត់ឱ្យបានឆាប់ ។ ដែនកំណត់នេះ ត្រូវបានរំពឹងទុកថានឹងចាប់ផ្តើមនៅ ចុងរដូវក្តៅ ។ នឹងមានកិច្ចប្រជុំកំណត់ដែនកំណត់ពីរ ក្នុងកំឡុងពេលផ្តល់យោបល់ជាសាធារណៈនេះ ។
- ការផ្តល់ព័ត៌មានស្តីពីការសិក្សាត្រួតពិនិត្យលើ EIS អាចផ្តល់ដោយផ្ទាល់មាត់ នៅក្នុងកិច្ចប្រជុំជាសាធារណៈ ឬសរសេរជាលិខិតផ្ញើរមកពេលណាក៏បាន ក្នុងអំឡុងពេលផ្តល់មតិយោបល់ ។ ព័ត៌មានលំអិតស្តីពីទីកន្លែងត្រូវផ្ញើរលិខិតបញ្ចេញមតិយោបល់ជាលាយលក្ខណ៏អក្សរនឹងផ្តល់ជូនពេលដែលរយៈពេលសិក្សាត្រួតពិនិត្យ ត្រូវបានប្រកាសឱ្យដឹងជាផ្លូវការ ។

### *តើមានរឿងអ្វីកើតឡើងបន្ទាប់ពីដំណើរការសិក្សាត្រួតពិនិត្យ ?*

- ផ្អែកទៅលើមតិយោបល់ដែលទទួលបានពីក្នុងអំឡុងពេលសិក្សាត្រួតពិនិត្យ ក្រុងនឹងបញ្ចប់ការសិក្សាត្រួតពិនិត្យលើ EIS ។
- បន្ទាប់មក ក្រុងនឹងរៀបចំពង្រាង EIS ។

## តើពង្រាង EIS ជាអ្វីទៅ ?

- ពង្រាង EIS គឺជាការវិភាគទូលំទូលាយជំហានដំបូងរបស់ក្រុង ស្តីពីផលប៉ះពាល់បរិស្ថាននៃជម្រើសផ្សេងៗ ក្រោមប្រធានបទជាច្រើន ដូចជា : ដីគោក ដីលិចទឹក ការប្រើប្រាស់ដី សំលេង មធ្យោបាយដឹកជញ្ជូន ។ល ។
- ពង្រាង EIS ត្រូវចេញផ្សាយ និងចែកជូនដល់ភ្នាក់ងារផ្សេងៗ និងសាធារណៈជន ឱ្យពិនិត្យឡើងវិញ ដែលជាផ្នែកមួយនៃរយៈពេលផ្តល់មតិយោបល់សាធារណៈលើកទីពីរ ។
- កិច្ចប្រជុំសាធារណៈ ត្រូវរៀបចំឡើងបន្ទាប់ពីការចេញផ្សាយពង្រាង EIS ដើម្បីប្រមូលមតិយោបល់ពាក់ព័ន្ធទៅនឹងពង្រាង EIS ។ មតិយោបល់លើពង្រាង EIS អាចផ្តល់ដោយផ្ទាល់មាត់ ក្នុងកិច្ចប្រជុំជាសាធារណៈ ឬសរសេរជាលិខិតផ្ញើមកក្នុងពេលណាមួយ ក្នុងអំឡុងពេលផ្តល់មតិយោបល់លើកទីពីរ ។

## តើ EIS ចុងក្រោយជាអ្វី ?

- ផ្អែកលើមតិយោបលទទួលបានពីពង្រាង EIS, EIS ចុងក្រោយរៀបចំឡើងជាជំហានទីបី និងចុងក្រោយក្នុងដំណើរការ EIS ។ EIS ចុងក្រោយ ផ្តល់ការឆ្លើយតបទៅនឹងមតិយោបល់ ដែលទទួលបានពីពង្រាង EIS ពីភ្នាក់ងារ អង្គការផ្សេងៗ និងសាធារណៈជន ហើយអាចមានសរសេរបំណកស្រាយផ្សេងៗ ចំពោះការវិភាគស្តីពីផលប៉ះពាល់បរិស្ថាន ។
- EIS ពង្រាង និងចុងក្រោយទាំងពីរនេះ មានឯកសារដែលក្រុងនឹងប្រើប្រាស់ - ផ្គូបផ្គងជាមួយនឹងព័ត៌មានវិភាគ និងពីសាធារណៈជន - ក្នុងការជ្រើសរើសទីតាំងសំរាប់សាងសង់ពន្ធនាគារក្រុង Seattle និងសំរាប់ការសំរេចចិត្តផ្សេងៗលើគម្រោងនេះ ។

## តើកាលបរិច្ឆេទរៀបចំឡើងសំរាប់ EIS មានអ្វីខ្លះ ?

- សិក្សាត្រួតពិនិត្យ - រៀបចំឡើងនៅរដូវក្តៅ ឆ្នាំ 2008
- EIS ព្រាង - នឹងត្រូវចេញផ្សាយនៅត្រីមាសទីមួយ ឆ្នាំ 2009
- EIS ចុងក្រោយ - ចេញផ្សាយផ្សាយនៅរដូវស្លឹកឈើលាស់ ឆ្នាំ 2009

## តើមានអ្វីកើតឡើងក្រោយពី EIS ចុងក្រោយ

- លោកអភិបាលក្រុងនឹងផ្តល់អនុសាសន៍ទៅឱ្យក្រុមប្រឹក្សាក្រុង ពាក់ព័ន្ធទៅគម្រោងពន្ធនាគារក្រុង Seattle ។
- ក្រុមប្រឹក្សាក្រុងនឹងត្រួតពិនិត្យជម្រើសសាងសង់ពន្ធនាគារដោយខ្លួន ដែលនឹងរួមបញ្ចូលឱកាសសាងសង់ជាផ្លូវការច្រើនជាងមុនសម្រាប់ការទទួលបានព័ត៌មានពីសាធារណៈជន ។
- ឱកាសជាបន្តបន្ទាប់សម្រាប់ការទទួលព័ត៌មានពីសាធារណៈជន នឹងកើតមានឡើងជាផ្នែកមួយដំណើរការសំរេចចិត្ត ។
- ក្រុមប្រឹក្សាក្រុង នឹងធ្វើការសំរេចចិត្តជាលើកចុងក្រោយ លើទីតាំងដែលត្រូវសាងសង់ពន្ធនាគារថ្មី ។